# Monthly Report Volume 38

February 2025

**Project Activities:**

- 3rd Feb: - Monthly Meeting with JICA HQ / Cambodia Office
  - Meeting with Asst. Prof. TOUCH Sokneang
- 17th Feb: Dr. Yamamoto Joining the Project
- 19th Feb: Meeting with CCN
- 20th Feb: Meeting with CAN
- 26th Feb: Study Tour from Nagano College of Nursing

**សកម្មភាពគម្រោង៖**

- ថ្ងៃទី ៣ ខែកុម្ភៈ៖ - ការប្រជុំប្រចាំខែជាមួយ ការិយាល័យកណ្ដាល JICA និងការិយាល័យ JICA នៅប្រទេសកម្ពុជា
  - ការប្រជុំជាមួយលោកស្រីសាស្ត្រាចារ្យជំ. ទូច សុខនាង
- ថ្ងៃទី ១៧ ខែកុម្ភៈ៖ ស្វាគមន៍លោកស្រីបណ្ឌិត YAMAMOTO ចូលរួមក្នុងគម្រោងនេះ។
- ថ្ងៃទី ១៩ ខែកុម្ភៈ៖ កិច្ចប្រជុំជាមួយនឹងគណៈគិលានុបដ្ឋាកកម្ពុជា
- ថ្ងៃទី ២០ ខែកុម្ភៈ៖ កិច្ចប្រជុំជាមួយនឹងសមាគមគិលានុបដ្ឋាកកម្ពុជា
- ថ្ងៃទី ២៦ ខែកុម្ភៈ៖ ដំណើរទស្សនកិច្ចសិក្សាពីមហាវិទ្យាល័យគិលានុបដ្ឋាក Nagano

## Courtesy Meeting with Cambodian Association of Nurses (CAN)

## កិច្ចប្រជុំដើម្បីសម្តែងការគួរសមជាមួយសមាគមគិលានុបដ្ឋាកកម្ពុជា

On February 20th, the Project held a meeting with the CAN President, Ms. Pay Soklim, at the National Pediatric Hospital. The purpose of the meeting was to exchange views with the CAN President on the role of continuing professional development training in enhancing the competence of nurses in Cambodia. She also shared recent advancements in CAN's activities. Additionally, the three new experts introduced themselves to her, and they reaffirmed their commitment to continued cooperation.

កាលពីថ្ងៃទី២០ ខែកុម្ភៈ គម្រោង Strings បានជួបពិភាក្សាជាមួយលោកស្រី ប៉ៃ សុខលីម ប្រធានសមាគមគិលានុបដ្ឋាកកម្ពុជា នៅមន្ទីរពេទ្យកុមារជាតិ។ កិច្ចប្រជុំនេះ មានគោលបំណង ផ្លាស់ប្តូរមតិយោបល់គ្នាពីសារៈសំខាន់នៃការអភិវឌ្ឍវិជ្ជាជីវៈបន្តដើម្បីធ្វើឱ្យសមត្ថភាពគិលានុបដ្ឋាកប្រសើរឡើង នៅក្នុងប្រទេសកម្ពុជា។ លោកស្រី ប៉ៃ សុខលីម បានចែករំលែកអំពីសមិទ្ធផលដែលសមាគមគិលានុបដ្ឋាកទទួលបានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះផងដែរ។ បន្ថែមពីលើនេះ គម្រោងក៏បានណែនាំអ្នកជំនាញការថ្មីចំនួន ៣ រូប ហើយពួកគាត់ក៏បានបង្ហាញពីការប្តេជ្ញាចិត្តដើម្បីបន្តកិច្ចសហប្រតិបត្តិការក្នុងគម្រោងនេះ។

## Courtesy Meeting with Cambodian Council of Nurses (CCN)

## កិច្ចប្រជុំដើម្បីសម្តែងការគួរសមជាមួយគណៈគិលានុបដ្ឋាកកម្ពុជា

On February 19th, the project team met with CCN President Mr. Chea Sopheakmoniroth and members at Calmette Hospital. The purpose of this discussion was to exchange perspectives on CCN's role in enhancing nursing quality in Cambodia, particularly through CPD training aligned with the project's objectives. Additionally, the project introduced three newly appointed experts. Both sides also explored potential areas for collaboration, discussing ways to work together to strengthen nursing education and professional development.

នៅថ្ងៃទី១៩ ខែកុម្ភៈ ក្រុមការងារគម្រោងបានជួបជាមួយលោក ជា សុភ័ក្រមុនីរ័ត្ន ប្រធាន CCN និងសមាជិក នៅមន្ទីរពេទ្យកាល់ម៉ែត។ គោលបំណងនៃកិច្ចពិភាក្សានេះ គឺដើម្បីផ្លាស់ប្តូរមតិយោបល់ពីតួនាទីរបស់ CCN ក្នុងការលើកកម្ពស់គុណភាពនៃការថែទាំនៅក្នុងប្រទេសកម្ពុជា តាមរយៈការបណ្តុះបណ្តាល CPD ដែលស្របតាមគោលបំណងនៃគម្រោង។ លើសពីនេះ គម្រោងបានណែនាំអ្នកជំនាញការថ្មីដែលចូលបន្តការងារចំនួន ៣ រូបផងដែរ។ ភាគីទាំងពីរក៏បានស្វែងយល់ពីសក្តានុពលនៃកិច្ចសហប្រតិបត្តិការ និងបានពិភាក្សាពីវិធីសាស្ត្រក្នុងការធ្វើការរួមគ្នា ដើម្បីពង្រឹងការអប់រំរបស់គិលានុដ្ឋាក និងការអភិវឌ្ឍវិជ្ជាជីវៈ។





Meeting with CCN



Meeting with CAN

# MESSAGE from Chief Advisor

**Dr. HIURA Mizue started working for Strings Project from December 2021 until February 2025.**

> **"As my time in Cambodia wraps up, I want to express my heartfelt thanks to my amazing colleagues and counterparts. It's been a privilege to work alongside such dedicated professionals. I'm excited to see how the work we've started will continue to grow. Best of luck in everything ahead!"**



**Ms. HIURA Mizue**

លោកស្រីបណ្ឌិត **HIURA Mizue** បានចាប់ផ្តើមចូលធ្វើការនៅក្នុងគម្រោង **Strings** ចាប់តាំងពីខែធ្នូ ឆ្នាំ២០២១ រហូតដល់ខែកុម្ភៈ ឆ្នាំ ២០២៥។

> "អំឡុងពេលដែលវេលារបស់ខ្ញុំធ្វើការនៅប្រទេសកម្ពុជាបានបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះក្រុមការងារ និងសមាភាគីដ៏អស្ចារ្យរបស់ខ្ញុំ។ ខ្ញុំពិតជាមានកត្តិយសណាស់ដែលបានធ្វើការជាមួយនឹងអ្នកជំនាញប្រកបដោយការតាំងចិត្តខ្ពស់បែបនេះ។ ខ្ញុំពិតជារំភើបក្នុងការមើលពីការរីកចម្រើនបន្តទៀតនៃការងារដែលយើងបានចាប់ផ្តើមក្នុងគម្រោងនេះ។ សូមសំណាងល្អសម្រាប់សកម្មភាពបន្តបន្ទាប់!"

**On 7th June 2024, Ms. TANAKA Sae came to Cambodia to work as the temporary Project Coordinator/Nursing Training Management for 2 months from July until August of 2024. In January 2025, Ms. Tanaka returned back to work as the new Nursing Education Expert. She will take on the post for 2 years until the project wraps up.**



**Ms. TANAKA Sae**

នៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០២៤ លោកស្រី **Tanaka Sae** បានមកប្រទេសកម្ពុជាដើម្បីធ្វើការជាអ្នកសម្របសម្រួលគម្រោង/រៀបចំការបណ្តុះបណ្តាលសម្រាប់គិលានុបដ្ឋាករយៈពេលខ្លី បានរយៈពេល ២ ខែ ចាប់ពីខែកក្កដា រហូតដល់ខែសីហា ឆ្នាំ ២០២៤។ នៅខែមករា ឆ្នាំ ២០២៥ លោកស្រី **Tanaka** បានត្រឡប់មកធ្វើការជាអ្នកជំនាញផ្នែកអប់រំការថែទាំ។ លោកស្រីនឹងបន្តកាន់តំណែងនេះរយៈពេល ២ ឆ្នាំ រហូតដល់បញ្ចប់គម្រោង។

# Information ព័ត៌មាន

**On 17th February, 2025, the project team was welcome Dr. YAMAMOTO Yoko as the new Project Chief Advisor, succeeding Dr. Hiura Mizue. Dr. Yamamoto brings a wealth of experience from her work as a Nursing Education Expert in JICA's technical cooperation projects in Mongolia and Bangladesh.**



**Ms. YAMAMOTO Yoko**

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រុមការងារគម្រោងបានទទួលស្វាគមន៍លោកស្រីបណ្ឌិត **YAMAMOTO Yoko** ជាប្រធានទីប្រឹក្សាគម្រោងថ្មី បន្តពីលោកស្រីបណ្ឌិត **Hiura Mizue**។ លោកស្រីបណ្ឌិត **YAMAMOTO** នាំមកនូវបទពិសោធន៍ជាច្រើនពីការងាររបស់គាត់ដែលជាអ្នកជំនាញផ្នែកអប់រំការថែទាំនៅក្នុងគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់ **JICA** នៅក្នុងប្រទេសម៉ុងហ្គោលី និងបង់ក្លាដែស។

**Ms. BUN Yalinna, Project officer, left the project on 14th February to take the next step in her career. We appreciate her contributions and wish her success in the future.**

កញ្ញា ប៊ុន យ៉ាលីនណា បុគ្គលិកគម្រោងបានចាកចេញពីគម្រោងកាលពីថ្ងៃទី១៤ ខែកុម្ភៈ ដើម្បីឈានទៅជំហានបន្ទាប់ក្នុងអាជីពរបស់គាត់។ យើងសូមកោតសរសើរចំពោះការរួមចំណែកក្នុងសកម្មភាពគម្រោង ហើយសូមជូនពរឱ្យគាត់ទទួលបានភាពជោគជ័យនាពេលអនាគត។



**Ms. BUN Yalinna**

## UPCOMING ACTIVITIES
## សកម្មភាពនាពេលខាងមុខ

- 3rd Mar: Monthly Meeting with JICA HQ / Cambodia Office
- 13th Mar: Meeting with HRDD / JICA HQ / Cambodia Office
- 14th Mar: Meeting with KC PHD / RTC / JICA HQ / Cambodia Office

- ថ្ងៃទី៣ ខែមិនា៖ កិច្ចប្រជុំប្រចាំខែជាមួយការិយាល័យកណ្តាល JICA/ការិយាល័យកម្ពុជា
- ថ្ងៃទី១៣ ខែមិនា៖ កិច្ចប្រជុំជាមួយនឹងHRDD/ ការិយាល័យកណ្តាល JICA/ការិយាល័យ JICA នៅកម្ពុជា
- ថ្ងៃទី១៤ ខែមិនា៖ កិច្ចប្រជុំជាមួយនឹងមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកំពង់ចាម/RTC/ការិយាល័យកណ្តាល JICA/ការិយាល័យ JICA នៅកម្ពុជា

## CONTACT INFORMATION

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2, Tuol Kork District, Phnom Penh, Cambodia

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh, Cambodia

**Email: info@jicastrings.com**

**Scan here to find out more about us:**



JICA's FB Page

Project's Homepage